ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៧៦៤ សរណ.កសក

# សេចក្តីជូនដំណឹង

## ស្តីពី

## លក្ខខណ្ឌតម្រូវនៃការធ្វើពាណិជ្ជកម្មនាំចេញគោ ក្របីរស់

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ក្រុមហ៊ុន និងអាជីវករដែលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យនាំចេញគោ ក្របីរស់ទាំងអស់ជ្រាបថា ដើម្បីពង្រឹងការគ្រប់គ្រងលើការចរាចរណ៍សត្វ និងទប់ស្កាត់ជំងឺឆ្លងសត្វ ព្រមទាំងឆ្លើយតបទៅនឹងការលើកកម្ពស់គុណភាព និងសុខុមាលភាពសត្វស្របតាមស្តង់ដារនៃការធ្វើពាណិជ្ជកម្មនាំចេញគោ ក្របីរស់នោះ ក្រុមហ៊ុន និងអាជីវករខាងលើ ត្រូវចាត់ចែងបំពេញនីតិវិធី និងលក្ខខណ្ឌដូចខាងក្រោម៖

- ជាក្រុមហ៊ុនស្របច្បាប់ដែលបានចុះបញ្ជីពាណិជ្ជកម្ម និងមានប័ណ្ណប៉ាតង់សុពលភាព
- ត្រូវមានទីតាំងប្រមូលផ្តុំនិងបំប៉នសត្វ ដែលទទួលស្គាល់ដោយសមត្ថកិច្ចជំនាញ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវចុះកិច្ចសន្យាបច្ចេកទេសជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវធានាអនុវត្តកិច្ចសន្យានេះឱ្យបានត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស និងការធ្វើចត្តាឡីស័ក
- ត្រូវអនុវត្តលក្ខខណ្ឌបង្ការជំងឺឆ្លង ជាពិសេសការតម្រូវចាក់វ៉ាក់សាំងការពារជំងឺអុតក្តាមឱ្យបានសមស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវអនុវត្តតាមប្រកាសលេខ២២៧ ប្រក.កសក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីបែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក
- ត្រូវអនុវត្តតាមប្រកាសលេខ៣៦០ ប្រក.កសក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រង និងដាក់ឱ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុន អាជីវករ ត្រូវសហការបំពេញនូវបែបបទជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចាប់ពីពេលជូនដំណឹងនេះ រហូតដល់ខែកក្កដា ឆ្នាំ២០១៨ ហើយក្រសួងមិនទទួលខុសត្រូវចំពោះក្រុមហ៊ុន ឬអាជីវករដែលមិនបានបំពេញតាមការណែនាំខាងលើ ចាប់ពីខែសីហា ឆ្នាំ២០១៨តទៅ។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងព័ត៌មាន
- រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឳវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
... Sangkat Tonle Bassak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320